សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
**LICADHO**
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

សេចក្ដីថ្លែងការណ៍

# អង្គការ លីកាដូ បង្ហាញទិន្នន័យដីសម្បទានរបស់ខ្លួន និងស្នើសុំយ៉ាងទទូចនូវទិន្នន័យដែលមានតម្លាភាពពីរាជរដ្ឋាភិបាល

ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៥

នាថ្ងៃនេះ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស "លីកាដូ" នឹងធ្វើការចេញផ្សាយជាសាធារណៈនូវទិន្នន័យអំពីដីសម្បទានរបស់ខ្លួន ហើយសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមលោកមេត្តាអនុវត្តតាមពាក្យសុំក្នុងការបង្ហាញជាសាធារណៈនូវព័ត៌មានលំអិតនៃដីសម្បទានទាំងអស់ដែលត្រូវបានផ្ដល់នៅក្នុងប្រទេសកម្ពុជា។ ព័ត៌មានដែលចេញផ្សាយនេះ គឺត្រូវបានចងក្រងក្នុងរយៈពេល ៥ឆ្នាំនៃការស៊ើបអង្កេតទៅលើវិស័យនេះ។

នៅខែឧសភា ២០១២ សម្ដេចនាយករដ្ឋមន្ត្រី លោកបានចុះហត្ថលេខាលើបទបញ្ជាមួយដោយផ្អាកការផ្ដល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗបន្តទៀត។ បទបញ្ជានេះ ក៏បានប្រកាសឲ្យមានការពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចពីមុនៗ។ ការពិនិត្យឡើងវិញនេះ អាចនឹងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវតែក្នុងករណីដែលរាជរដ្ឋាភិបាលបង្ហាញជាសាធារណៈនូវចំនួនដីសម្បទានទាំងអស់ដែលត្រូវបានផ្ដល់។ ប៉ុន្តែ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាល មិនទាន់បានបង្ហាញឲ្យបានអស់នៃដីសម្បទានដែលត្រូវបានផ្ដល់ទៅឲ្យឯកជននោះទេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញផ្សាយនូវបញ្ជីឈ្មោះក្រុមហ៊ុនមួយដែលមានលក្ខណៈមិនពេញលេញ។ រីឯក្រសួងបរិស្ថាន រឹតតែអនុវត្តតិចជាងក្រសួងកសិកម្មទៅទៀត ដោយគ្រាន់តែបង្ហាញចំនួនក្រុមហ៊ុនសរុបដែលពាក់ព័ន្ធ និងចំនួនសរុបដីសម្បទានដែលត្រូវបានផ្ដល់ប៉ុណ្ណោះ។ ហើយក្រសួងទាំងពីរក៏មិនទាន់បានបង្ហាញនូវទីតាំងជាក់លាក់នៃដីចំនួន ២,១ លានហិកតា ដែលជាដីសម្បទានសេដ្ឋកិច្ចផងដែរ។

ណាលី ពីឡុក នាយិកាអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖ "ដីសម្បទានទំហំធំៗ ធ្លាប់មានប្រវត្តិប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងធនធានធម្មជាតិ ក៏ដូចជាមានផលប៉ះពាល់ជាអវិជ្ជមានដល់ការអនុវត្តគម្រោងនានាផងដែរ។ ប្រសិនបើរាជរដ្ឋាភិបាល តាំងចិត្តក្នុងការធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលទៅលើវិស័យដីធ្លី នោះត្រូវតែប្ដេជ្ញាចិត្តក្នុងការអនុវត្តការងារប្រកបដោយតម្លាភាពទៅលើការផ្ដល់ដីសម្បទានរបស់រដ្ឋ។" អ្នកនាង បានមានប្រសាសន៍បន្តទៀតថា៖ "ប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិ និងត្រូវការទទួលព័ត៌មានអំពីអ្នកដែលគ្រប់គ្រងតំបន់ទាំងនោះដែលនៅជិតនឹងផ្ទះរបស់អ្នកទាំងនោះ។"

អង្គការ លីកាដូ សូមសំណូមពរដ៏ទទូចដល់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា សូមលោកមេត្តាធ្វើការអនុវត្តការវាយតម្លៃជាសាធារណៈមួយទៅលើការទទួលបានដីសម្បទានធំៗទាំងនោះ។ ការវាយតម្លៃនេះ នឹងត្រូវការឲ្យមានការប្រកាសឲ្យបានពេញលេញពីគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់នូវប្រាក់ចំណូលចូលរដ្ឋទាំងអស់ដែលបានមកពីដីសម្បទានសេដ្ឋកិច្ចទាំងនោះ។

ដោយសារការខ្វះនូវតម្លាភាពរបស់រាជរដ្ឋាភិបាល ព័ត៌មានដែលអង្គការ លីកាដូ បានចងក្រងក្នុងរយៈពេល ៥ឆ្នាំ នៅតែមិនទាន់ពេញលេញ និងមានចំនុចមួយចំនួនមិនទាន់ច្បាស់លាស់។ ដូចនេះហើយ មិនមានអ្វីដែលជំនួសឲ្យការបង្ហាញជាសាធារណៈនូវទិន្នន័យរបស់រាជរដ្ឋាភិបាលដោយផ្ទាល់នោះទេ។

លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ បានមានប្រសាសន៍ថា៖ "អង្គការ លីកាដូ សង្ឃឹមថា ព័ត៌មានបន្ថែមទៅលើការផ្តល់ដីសម្បទានទំហំធំៗទាំងនោះ អាចជួយឲ្យមានការវិវឌ្ឍន៍ទៅមុខនៅក្នុងការពិភាក្សាទៅលើប្រធានបទប្រភេទនេះ។ អង្គការ លីកាដូ ក៏នៅតែចង់បានព័ត៌មានបន្ថែមពីរាជរដ្ឋាភិបាល។" លោក បានមានប្រសាសន៍បន្ថែមទៀតថា៖ "អាចជាការយឺតយ៉ាវបន្តិចសម្រាប់ប្រទេសកម្ពុជា ក្នុងការធ្វើការវាយតម្លៃអំពីគុណប្រយោជន៍ និងគុណវិបត្តិនៃប្រធានបទបែបនេះ។"

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

- លោក អំ សំអាត, អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ, ទូរស័ព្ទលេខ៖ ០១២ ៣២៧ ៧៧០ (ភាសាខ្មែរ)
- អ្នកនាង ណាលី ពីឡូក, នាយិកាអង្គការ លីកាដូ, ទូរស័ព្ទលេខ៖ ០១២ ៨០៣ ៦៥០ (ភាសាអង់គ្លេស)